**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(៥៥*៦២)

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មាន
# ស្តីពីការហាមឃាត់គណនីបណ្តាញសង្គមហ្វេសប៊ុកកំពុងផ្សព្វផ្សាយលក់ផលិតផល FINGERROOT គ្មានលេខបញ្ជិកាពីក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថាៈ យោងតាមការពិនិត្យឃើញលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) មានគណនីឈ្មោះ ឱសថបុរាណថៃ ស្តេចខ្លាយស និង ស្តេចខ្ចី แพทย์แผนไทย កំពុងផ្សព្វផ្សាយលក់ផលិតផលឈ្មោះ FINGERROOT ដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជំងឺ គ្មានលេខបញ្ជិកាពីក្រសួងសុខាភិបាលគិតត្រឹមថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០២១។

*អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងឱសថ តម្រូវឱ្យរាល់ការចរាចរផលិតផលឱសថ ឬផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជំងឺគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលេខទិដ្ឋាការ ឬលេខបញ្ជិកាពីក្រសួងសុខាភិបាល។ ដូច្នេះ សូមប្រជាពលរដ្ឋមុននឹងទិញផលិតផលឱសថ ឬផលិតផលបំប៉នសុខភាពគ្រប់ប្រភេទ សូមពិនិត្យមើលលតាបត្របញ្ជិកាដែលមានបិទលើសំបកវេចខ្ចប់ ហើយលតាបត្រដែលត្រឹមត្រូវគឺមានពីរផ្នែក ១-ផ្នែកខាងលើមានឈ្មោះ គ្រឹះស្ថានអាហារ័ណ នីហរ័ណឱសថ ២-ផ្នែកខាងក្រោមមានលេខទិដ្ឋាការ ឬបញ្ជិកា ដូចមានគំរូភ្ជាប់ជាមួយ។*

ក្រសួងសុខាភិបាល សូមជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឈប់ជឿការផ្សព្វផ្សាយផលិតផល FINGERROOT គ្មានលេខបញ្ជិកាតាមគណនីបណ្តាញសង្គមហ្វេសប៊ុកខាងលើ និងឈប់ប្រើប្រាស់ផលិតផលគ្មានលេខបញ្ជិកានេះជាបន្តទៀត។ ម្ចាស់គណនីបណ្តាញសង្គមហ្វេសប៊ុកខាងលើ និងជនពាក់ព័ន្ធដទៃទៀតត្រូវបញ្ឈប់ការនាំចូល ចែកចាយ ឬផ្សព្វផ្សាយលក់ផលិតផល FINGERROOT ដែលគ្មានលេខបញ្ជិកាខាងលើជាបន្ទាន់។

ក្រសួងសុខាភិបាល នឹងមានវិធានការតឹងរ៉ឹងទៅតាមផ្លូវច្បាប់ចំពោះម្ចាស់គណនីខាងលើ និងជនពាក់ព័ន្ធទាំងឡាយណាដែលនាំចូល ចែកចាយ ឬផ្សព្វផ្សាយលក់ ផលិតផល FINGERROOT ដែលគ្មានលេខបញ្ជិកាខាងលើទៅតាមច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថជាធរមាន។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋបានជួបប្រទះឃើញជនណាកំពុងចែកចាយ ឬលក់ផលិតផល FINGERROOT គ្មានលេខបញ្ជិកាខាងលើនេះ សូមបងប្អូនប្រញាប់ផ្តល់ព័ត៌មាន ឬត្រូវការព័ត៌មានបន្ថែមពីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទៈ ០១២ ៣៥៥ ១៦១, ០១១ ៥៧៤ ៧៨៧, ០១២ ៩៨៣ ៣៣៤, ០១៧ ៦០៦ ៦៧០, ០១២ ៥៦២ ៤៤៦, ០១៧ ៨៦៦ ៧៦០។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ខែ កញ្ញា ឆ្នាំ ២០២១

# ឈ្មោះគណនីបណ្តាញសង្គមហ្វេសប៊ុក ឱសថបុរាណថៃ ស្តេចខ្ញាយស និង ស្តេចខ្ញី แพทย์แผนไทย និងផលិតផលឈ្មោះ FINGERROOT គ្មានលេខបញ្ជិកាពីក្រសួងសុខាភិបាល




## គំរូលតាបត្រផលិតផលបំប៉នសុខភាព

| | | |
|---|---|---|
| XYXZ Pharma Co.,LTD | SPKLA HEALTHCARE Co.,LTD | XMX TRADING Co.,LTD |
| CAM N 1199 IH-20 | CAM $R_1$ 03109 IH-16 | CAM $R_2$ 1019 IH-15 |